# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រម

០២-៤-២០០៥ -ព្រះរាជក្រម នស/រកម/០៤០៥/០១២ ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ៣០០១

០២-៤-២០០៥ -ព្រះរាជក្រម នស/រកម/០៤០៥/០១៣ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងមូលដ្ឋាន ស្តីពីកម្មវិធីសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO) ៣០១២

### ២_ព្រះរាជក្រឹត្យ

២១-១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០១៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ៣០២៤ក

២៣-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៩១ ស្តីពី ការតែងតាំងលោក **ជីម ម៉ុនវឌ្ឍមុនី** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៣០២៥

០៦-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២០៣ ស្តីពី ការប្រោសព្រះរាជទានចំពោះឯកឧត្តម **ស៊ូ តិរិទ្ធ** នូវ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ៣០២៦

០៦-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២០៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៣០២៧

០៦-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២០៥ ស្តីពី ការតែងតាំងឯកឧត្តម **មាស សារិន** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ៣០២៨

០៧-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២០៦ ស្តីពី ការប្រោសព្រះរាជទានចំពោះឯកឧត្តម **ហេង ចន្ទម៉ុនឆាត** ទីប្រឹក្សារាជរដ្ឋាភិបាល នូវ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ៣០២៩

០៧-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២០៦ ស្ទួន ស្តីពី ការប្រោសព្រះរាជទានចំពោះ Son Excellence Monsieur CLAUDE GOUR Conseiller Juridique du Gouvernement នូវ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ៣០៣០

០៦-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២០៧ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **ឡុង លីម** នាយនគរបាល ជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៣០៣១

០៧-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២០៨ ស្តីពីការតែងតាំង និងសំរួលភារកិច្ចជូនឯកឧត្តម ចំនួន ០២ រូប ៣០៣២

០៧-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២០៩ ស្តីពីការតែងតាំងមន្ត្រីរាជការ ៣០៣៣

០៧-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២១០ ស្តីពីការតែងតាំងលោកជំទាវ **គីម នាង** ជាឧបការីសម្តេចក្រុមព្រះ សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ទទួលបន្ទុកការងារអភិវឌ្ឍន៏ប្រទេសកម្ពុជា ៣០៣៤

០៩-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២១២ ស្តីពី ការប្រោសព្រះរាជទានចំពោះឯកឧត្តម **មិន ឃិន** នូវ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ៣០៣៥

## II_រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៦-៥-២០០៥ -អនុក្រឹត្យលេខ ៤២០ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល អគ្គនាយក និង មន្ត្រីត្រួតពិនិត្យរដ្ឋ នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជា រី " ៣០៣៦

០៧-៥-២០០៥ -អនុក្រឹត្យលេខ ៤២១ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ៣០៣៨

០៧-៥-២០០៥ -អនុក្រឹត្យលេខ ៤២២ អនក្រ.តត ស្តីពីការ ជូនមេដាយសហមេត្រី ៣០៤០

០៧-៥-២០០៥ -អនុក្រឹត្យលេខ ៤២៣ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ៣០៤១

០៧-៥-២០០៥ -អនុក្រឹត្យលេខ ៤២៤ អនក្រ.តត ស្តីពីការ ជូនមេដាយសហមេត្រី ៣០៤២

## III_ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

០៩-៥-២០០៥ -ប្រកាសលេខ ៥៦១ ប្រក ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ៣០៤៣

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

០៦-៥-២០០៥ -ប្រកាសលេខ ១៦៤/០៥ ព.ម.ប្រក ស្តីពីការបង្កើតការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ៣០៤៤

## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៥-៤-២០០៥ -លិខិតលេខ ៩១៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ទណ្ណា ថុង អ៊ីមផត អិចផត** ៣០៥០

២៥-៤-២០០៥ -លិខិតលេខ ៩១៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សាមាគូ** ៣០៥២

២៥-៤-២០០៥ -លិខិតលេខ ៩២០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេស ខេ ខេ (ខេមបូឌា)** ៣០៥៤

២៥-៤-២០០៥ -លិខិតលេខ ៩២១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **(ខេមបូឌា)_មេថីល ទើក** ៣០៥៦

២៦-៤-២០០៥ -លិខិតលេខ ៩២២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេ ធី ស៊ី អ៊ិនធើណេសិនណល** ៣០៥៨

២៦-៤-២០០៥ -លិខិតលេខ ៩២៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ជ្រៃឃ្លាន អនិសង្ស អ៊ិនដាស្ទ្រី** ៣០៦០

២៦-៤-២០០៥ -លិខិតលេខ ៩២៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ថេក ឃែរ គ្រុប** ៣០៦២

២៦-៤-២០០៥ -លិខិតលេខ ៩២៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ុន_ស៊ូ អ៊ីមផត អិចផត** ៣០៦៤

២៦-៤-២០០៥ -លិខិតលេខ ៩២៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **មេគង្គ ហ្គោមីន** ៣០៦៦

២៦-៤-២០០៥ -លិខិតលេខ ៩២៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ម៉េកស៊ីស ហ្គោមីង ខបភើរេសិន អិលធីឌី** ៣០៦៨

២៦-៤-២០០៥ -លិខិតលេខ ៩៣០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេសអិមអ៊ី រីញូអេបល អេនើជី លីមីធីត** ៣០៧០

២៦-៤-២០០៥ -លិខិតលេខ ៩៣១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មហា ភា អ៊ីមផត អិចផត** ៣០៧១

២៧-៤-២០០៥ -លិខិតលេខ ៩៣២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឡូកូម៉ូ ហ្វ៊ូដ** ៣០៧៣

២៧-៤-២០០៥ -លិខិតលេខ ៩៣៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉េង លី (ខេមបូឌា)** ៣០៧៥

២៧-៤-២០០៥ -លិខិតលេខ ៩៣៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ភីអេសធី អ៊ីន** ៣០៧៧

២៧-៤-២០០៥ -លិខិតលេខ ៩៣៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ិន ចៀ ហ្គាមេន** ៣០៧៩

២៧-៤-២០០៥ -លិខិតលេខ ៩៣៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អានដា ហ្គាមេន (ខេមបូឌា)** ៣០៨០

២៧-៤-២០០៥ -លិខិតលេខ ៩៤៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេវើ ឡាក់ឃី អ៊ិនធើប្រាយ** ៣០៨១

២៧-៤-២០០៥ -លិខិតលេខ ៩៤៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេ.អេច.អេហ្វ ខមតេនី** ៣០៨៣

២៧-៤-២០០៥ -លិខិតលេខ ៩៤៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធីបូ ហាយហ្វាយ ត្រេឌីង** ៣០៨៥

២៧-៤-២០០៥ -លិខិតលេខ ៩៤៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ទត្តី គ្លូប៊ល ត្រេដ** ៣០៨៧

២៧-៤-២០០៥ -លិខិតលេខ ៩៤៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេ.ធី.អេស** ៣០៨៩

២៧-៤-២០០៥ -លិខិតលេខ ៩៥០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឡឺ ប្រ្លាន់ ភ្លីប** ៣០៩១

២៧-៤-២០០៥ -លិខិតលេខ ៩៥១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីលវ៉ូត (ខេមបូឌា)** ៣០៩៣

២៧-៤-២០០៥ -លិខិតលេខ ៩៥២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ាយស្តូន (ខេមបូឌា)** ៣០៩៥
២៧-៤-២០០៥ -លិខិតលេខ ៩៥៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប្រ្តូន អ៊ិនធើធេនមេន** ៣០៩៧
២៨-៤-២០០៥ -លិខិតលេខ ៩៥៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អា_ជូ អ៊ីមផត អិចផត** ៣០៩៩
២៩-៤-២០០៥ -លិខិតលេខ ៩៦០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជាយ ប៊ូ ខមតេនី** ៣១០១
២៩-៤-២០០៥ -លិខិតលេខ ៩៦៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឈួនផ្លាស (ខេមបូឌា)** ៣១០៣
២៩-៤-២០០៥ -លិខិតលេខ ៩៦៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ូណា_លីសា** ៣១០៥
២៩-៤-២០០៥ -លិខិតលេខ ៩៦៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេ អ ស៊ី** ៣១០៧
២៩-៤-២០០៥ -លិខិតលេខ ៩៦៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បន្ទាយស្រី អ៊ិនជីនារីង & ខនស្ត្រាក់សិន** ៣១០៩
២៩-៤-២០០៥ -លិខិតលេខ ៩៦៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យូនៀន ទូដ អ៊ិនវេសមេន** ៣១១១
២៩-៤-២០០៥ -លិខិតលេខ ៩៧០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បេស រ៉ូយ៉ាល់ (ខេ)** ៣១១៣
២៩-៤-២០០៥ -លិខិតលេខ ៩៧១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ថបអែង គ្លូប៊ល ត្រេដ** ៣១១៥
២៩-៤-២០០៥ -លិខិតលេខ ៩៧២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឈុន ឡុង ជេម ម៉ាញនីង** ៣១១៧
២៩-៤-២០០៥ -លិខិតលេខ ៩៧២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឈុន ឡុង ជេម ម៉ាញនីង** ៣១១៧

២៩-៤-២០០៥ -លិខិតលេខ ៩៧៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**តែ អៀក អេង ខូ អិលធីឌី** ៣១១៩

២៩-៤-២០០៥ -លិខិតលេខ ៩៧៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ូធ័រ ឃីង អ៊ិនធើប្រាយ** ៣១២១

០៣-៥-២០០៥ -លិខិតលេខ ៩៧៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេឡូក្លូប អេស៊ា** ៣១២៣

០៣-៥-២០០៥ -លិខិតលេខ ៩៧៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិម ឌី អេច ត្រាវែល** ៣១២៥

០៣-៥-២០០៥ -លិខិតលេខ ៩៧៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្គ្រីន ណេតវើក ស៊ីវីស** ៣១២៧

០៣-៥-២០០៥ -លិខិតលេខ ៩៨២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ាង ឌូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន** ៣១២៩

០៣-៥-២០០៥ -លិខិតលេខ ៩៨៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជេន គូ អ៊ីមផត អិចផត ខមភេនី** ៣១៣១

០៤-៥-២០០៥ -លិខិតលេខ ៩៨៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អា អ៊ី អាស ខបភើរេសិន** ៣១៣៣

០៥-៥-២០០៥ -លិខិតលេខ ១០០០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឃ្យូមេន ផៅវ័រ** ៣១៣៥

០៥-៥-២០០៥ -លិខិតលេខ ១០០២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ាប់ អភិវឌ្ឍន៍ ខនស្ត្រាក់សិន** ៣១៣៧

០៥-៥-២០០៥ -លិខិតលេខ ១០០៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វ៉ៃ យ៉ាត់** ៣១៣៩

០៥-៥-២០០៥ -លិខិតលេខ ១០០៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សេមស៊ុង អ៊ិនធើប្រាយ** ៣១៤១

០៥-៥-២០០៥ -លិខិតលេខ ១០០៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ផាប់ប៊ី ត្រាវែល** ៣១៤៣

០៥-៥-២០០៥ -លិខិតលេខ ១០១០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ៊ុង យី ដា ផ្លាស្ទិក ហ្វេកតើរី** ៣១៤៥

០៥-៥-២០០៥ -លិខិតលេខ ១០១៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិល ស៊ី ឌី (ខេមបូឌា) ខូ អិលធីឌី** ៣១៤៧

០៥-៥-២០០៥ -លិខិតលេខ ១០១៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ថៃ ទេង ហួត** ៣១៤៩

០៥-៥-២០០៥ -លិខិតលេខ ១០២០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធីតា អភិវឌ្ឍន៍** ៣១៥១

០៥-៥-២០០៥ -លិខិតលេខ ១០២៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អូឌីន~ទ៉ាញ (ខេមបូឌា)** ៣១៥៣

០៥-៥-២០០៥ -លិខិតលេខ ១០២៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដាប់បែលយូ ទីជី ឌីវេឡុបមេន** ៣១៥៥

០៦-៥-២០០៥ -ប្រកាស № ១៤៩ MOC/M 2005 ស្តីពីការបង្កើតគណៈកម្មការសំរាប់រៀបចំគំរោង
គាំទ្រលើវិស័យវាយនភ័ណ្ឌនៅក្នុងបរិបទនៃការបាត់បង់ប្រព័ន្ធអនុគ្រោះកូតានៅកម្ពុជា ៣១៥៧

# ព្រះរាជក្រម

នស/រកម/០៤០៥/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/១៩៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការទូទាត់ថវិកាជាតិរបស់រដ្ឋ

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.-

ត្រូវបានយល់ព្រមតាមការអនុវត្តន៍នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ។ ការអនុវត្តន៍នេះ លេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ ÷

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០១ | ការអនុវត្តន៍ថវិកា ឆ្នាំ ២០០១ |
|---|---|---|
| សរុបចំណូល [១] | ២.៨៧៦.០០០ | ២.៨០៣.២៦៤ |
| សរុបចំណាយ | ២.៨៧៦.០០០ | ២.៥២៥.៨៥០ |
| ចំនួនឱនភាពនៃគណនេយ្យចំណូល/ចំណាយ | - | - ១២២.១៨៦ |
| កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាដែលបានអនុវត្តដោយរតនាគារជាតិ | | |
| ចំណូលថវិកា | ១.៧៧៦.០០០ | ១.៥៨៤.៩៨២ |
| • ចំណូលចរន្ត | ១.៦២៦.០០០ | ១.៥២០.៣៥៣ |
| • ចំណូលជាមូលធនក្នុងប្រទេស | ២៥.០០០ | ៩.០៥៩ |
| • ចំណូលជាមូលធនក្រៅប្រទេស | ១២៥.០០០ | ៥៥.៥៧០ |
| ចំណាយថវិកា | ១.៧៧៦.០០០ | ១.៧០៧.១៦៨ |
| • ចំណាយចរន្ត | ១.៤២៦.០០០ | ១.៤១៥.៦៣៤ |
| • ចំណាយជាមូលធន | ៣៥០.០០០ | ២៩១.៥៣៤ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ | | |
| • ធនធានជាមូលធន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ៨១៨.២៨២ |
| • ចំណាយជាមូលធនដោយធនធាន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ៨១៨.២៨២ |

---

(១) ក្នុងនោះមានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានលើកឡើងនេះ គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិ និង មិនបានចុះកិច្ចបញ្ជីការគណនេយ្យនៅក្នុងលេខនាររតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះ គឺជាលទ្ធផលដែល សំរេចបានដោយមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្តល់មូលនិធិ ។

**មាត្រា ២.-**

ចំណូលថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកា នៅក្នុងតារាង “ក” ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០១ ត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូក នៅក្នុងតារាង “ខ” ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង “ខ១” ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ដែលបានសំរេចក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០១ និងដែលបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

លទ្ធផលសំរេចបានស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ផ្ទាល់ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០១ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកានិង ចំពោះចំណាយត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ហើយ ត្រូវបានបញ្ជាក់ជាបន្តបន្ទាប់នៅក្នុងតារាង “ក” និង “ខ” ដូចមានភ្ជាប់មកជាមួយច្បាប់ នេះ ។

តារាង “ខ២” ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារជាតិ ដែលបានសំរេចក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០១ និងត្រូវបានបែងចែកតាមក្រសួង និង ស្ថាបន័សាធារណៈប្រហាក់ប្រហែល ដោយអ្នកផ្តល់បរទេស ។

## ជំពូកទី ២

## បទប្បញ្ញត្តិ

## ស្តីពីកិច្ចប្រតិបត្តិការថវិកា

**មាត្រា ៣.-**

ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និង ផលទុន ព្រមទាំងការសំរេចបាននូវអំណោយ មូលនិធិបដិភាគ



12

និងធនធានដែលបានមកពីការខ្ចីដែលមានចែងនៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ មានចំនួនទឹកប្រាក់សរុប........................................... ១.៧៧៦.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់........................ ១.៥៨៤.៩៨២ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន................................ (-)១៩១.០១៨ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ÷

ចំណូលចរន្ត :

- គំរោង........................ ១.៦២៦.០០០ លានរៀល
- ការសំរេចបាន....... ១.៥២០.៣៥៣ លានរៀល
- មានចំនួនខ្វះ.......... (-)១០៥.៦៤៧ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស :

- គំរោង.............................. ២៥.០០០ លានរៀល
- ការសំរេចបាន........................ ៩.០៥៩ លានរៀល
- មានចំនួនខ្វះ.............. (-)១៥.៩៤១ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស :

- គំរោង........................... ១២៥.០០០ លានរៀល
- ការសំរេចបាន................. ៥៥.៥៧០ លានរៀល
- មានចំនួនខ្វះ............. (-)៦៩.៤៣០ លានរៀល

## មាត្រា ៤.-

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ មានចំនួនទឹកប្រាក់សរុប........................ ១.៧៧៦.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់........................ ១.៧០៧.១៦៨ លានរៀល

ដូច្នេះមានចំណាយខ្វះឥណទានថវិកាចំនួន......... (-)៦៨.៨៣២ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ÷

ចំណាយចរន្ត :

- គំរោង........................ ១.៤២៦.០០០ លានរៀល
- ការសំរេចបាន......... ១.៤១៥.៦៣៤ លានរៀល
- មានចំនួនខ្វះ............ (-)១០.៣៦៦ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

- គំរោង................................ ៣២៥.០០០ លានរៀល
- ការសំរេចបាន.............. ២៨៣.០១៩ លានរៀល
- មានចំនួនខ្វះ.............. (-)៤១.៩៨១ លានរៀល

ចំណាយជាមូលធននៃការវិលសំបំណុល ÷

- គំរោង.................................. ២៥.០០០ លានរៀល
- ការសំរេចបាន.......................៨.៥១៥ លានរៀល
- មានចំនួនខ្វះ.............. (-)១៦.៤៨៥ លានរៀល

**មាត្រា ៥.-**

ការអនុវត្តន៏កិច្ចប្រតិបត្តិការចំណូល និង ចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលបានសំរេចដោយរតនាគារជាតិ ដូចមានចែងនៅក្នុងមាត្រា ៣ និង មាត្រា៤ នៃច្បាប់នេះ បានបង្ហាញជាលទ្ធផលនូវឱនភាពគណនេយ្យនៃចំណូលនិងចំណាយដូចតទៅ ÷

- ចំណូលថវិកាដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ មានចំនួន........................................................................ ១.៥៨៤.៩៨២ លានរៀល
- ចំណាយថវិកាដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ មានចំនួន........................................................................ ១.៧០៧.១៦៨ លានរៀល
- ឱនភាពគណនេយ្យពិតនៃចំណូលនិងចំណាយ..... (-)១២២.១៨៦ លានរៀល

ឱនភាពគណនេយ្យនេះ គឺជាលទ្ធផលនៃ ÷

- អតិរេកនៃចំណូល និង ចំណាយចរន្ត............ (+)១០៤.៧១៩ លានរៀល
- និងឱនភាពនៅក្នុងកិច្ចប្រតិបត្តិការជាមូលធន.. (-)២២៦.៩០៥ លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ឱនភាពគណនេយ្យនៃចំណូល និង ចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ មានចំនួនទឹកប្រាក់ (-)១២២.១៨៦ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផលដែលបានបើកនៅក្នុងលេខនានៃរតនាគារជាតិ ។

## ជំពូកទី ៣
## បទប្បញ្ញត្តិស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទាន
## ក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅរតនាគារជាតិ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១

**មាត្រា ៦.–**

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ និង ដែលបានគ្រោងទុកសរុបចំណូលស្មើនឹងសរុបចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ មានចំនួនទឹកប្រាក់.................................................... ៧០០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់..................................... ៨១៨.២៨២ លានរៀល

ដូច្នេះមានចំនួនលើស...................................................... (+)១១៨.២៨២ លានរៀល

## ជំពូកទី ៤
## បទប្បញ្ញត្តិស្តីពី
## តុល្យភាពហិរញ្ញវត្ថុសាធារណៈសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១

**មាត្រា ៧.–**

តុល្យភាពហិរញ្ញវត្ថុសាធារណៈជាស្ថាពរនៃថវិកាទូទៅរបស់រដ្ឋបានបង្ហាញនូវប្រភេទនៃកិច្ចប្រតិបត្តិការដូចតទៅ ÷

- កិច្ចប្រតិបត្តិការថវិកា : តារាង “ក” : ចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង “ខ” : ចំណាយថវិកាទូទៅរបស់រដ្ឋ ។
- កិច្ចប្រតិបត្តិការនៃរតនាគារជាតិ ។
- ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋជាមួយនឹងធនាគារជាតិនៃកម្ពុជា ។

តុល្យភាពហិរញ្ញវត្ថុដែលសំរេចបានជាស្ថាពរ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ បានឆ្លុះបញ្ចាំងនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចខាងក្រោម ÷

ឯកតា: លានរៀល

| តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+) ឱនភាព(-) |
|---|---|---|
| I - ចំណូលក្នុងប្រទេស | ១.៥២៩.៤១២ | |
| ១ - ចំណូលចរន្ត | ១.៥២០.៣៥៣ | |
| ២ - ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ៩.០៥៩ | |
| II - ចំណាយថវិកា | ២.៥១៦.៩៣៥ | |
| ១ - ចំណាយចរន្ត | ១.៤១៥.៦៣៤ | |
| ២ - ចំណាយជាមូលធន [២] | ១.១០១.៣០១ | |
| ក្នុងនោះ ÷ | | |
| * វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ២៨៣.០១៩ | |
| - ដោយមូលនិធិថវិកា | ២៤៧.៥៩៥ | |
| • គំរោងវិនិយោគ (សាងសង់, ទិញសម្ភារៈ) | ១៩៤.២១៩ | |
| • បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៥៣.៣៧៦ | |
| - ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | ៣៥.៤២៤ | |
| * វិនិយោគសាធារណៈដោយហិរញ្ញប្បទានពីក្រៅប្រទេសផ្ទាល់ (ជំនួយគំរោងការ) | ៨១៨.២៨២ | |
| អតិរេកនៃថវិកាចរន្ត (តាមនិយមន័យសន្យាផ្តល់) | | (+) ១០៤.៧១៩ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្យាផ្តល់) | | (-) ៩៨៧.៥២៣ |
| III - កំណែតំរូវ | | (+) ៥៥.១៦០ [៣] |
| អតិរេកនៃថវិកាចរន្ត (តាមនិយមន័យបេឡា) | | (+) ១៥៩.៨៧៩ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យបេឡា) | | (-) ៩៣២.៣៦៣ |
| IV - ហិរញ្ញប្បទាននៃឱនភាព | | (+) ៩៣២.៣៦៣ |
| ១ - ហិរញ្ញប្បទានក្រៅប្រទេស | | (+) ៨៨៩.៣៦៦ |
| • ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | | (+) ៥៤.២៧៦ |
| • ជំនួយគំរោងការ | | (+) ៨៣៩.៣៨១ [៤] |
| • ការរំលស់បំណុលបរទេស | | (-) ៤.២៩១ |
| ២ - ហិរញ្ញប្បទានក្នុងប្រទេស | | (+) ១០.៧២៩ |
| • ហិរញ្ញប្បទានធនាគារ | | (-) ៦៣.៦៣១ |
| ក្នុងនោះ - ខ្ចីពីធនាគារ | | (-) ០.៦០៧ |
| - ការរំលស់បំណុលក្នុងប្រទេស | | (-) ៣.៦១៧ |
| • ប្រាក់បញ្ញើផ្សេងៗទៀតនៃរតនាគារ | | (+) ៧៤.៣៦០ |
| ៣ - កិច្ចប្រតិបត្តិការកំពុងដំណើរការ | | (+) ៣២.២៦៨ |

(២) មិនបានគិតការរំលស់បំណុល ៨.៥១៥ លានរៀលទេ ។

(៣) បំរែបំរួលសុទ្ធនៃអាណត្តិបើកប្រាក់ដែលមានសល់មិនទាន់បានបើកផ្តល់នៅរតនាគារ និង បុរេប្រទានត្រូវធ្វើនិយ័តភាវូបនីយកម្ម ។

(៤) ក្នុងនោះមានទឹកប្រាក់ចំនួន ២១.០៩៩ លានរៀល ដែលត្រូវរង់ចាំការប្រើប្រាស់ ។

# ជំពូកទី ៥

# បទប្បញ្ញត្តិស្តីពី

# ការទូទាត់ថវិការបស់ខេត្ត ក្រុង

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១

**មាត្រា ៨.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម. ០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងមាត្រា ១៧ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស/ រកម/១២០០/១២, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០០ ត្រូវបានយល់ព្រមតាមការអនុវត្តន៍នូវ កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលលេចចេញជាលទ្ធផល ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ÷

ឯកតា: រៀល

| កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិកា របស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០១ | ការអនុវត្តន៍ថវិកា ខេត្ត ក្រុងឆ្នាំ ២០០១ | លើស(+) ខ្វះ(-) |
|---|---|---|---|
| សរុបចំណូល | ៥៨.០០០.០០០.០០០ | ៧១.៥៩១.២០៤.៦៤៨ | +១៣.៥៩១.២០៤.៦៤៨ |
| សរុបចំណាយ | ៥៨.០០០.០០០.០០០ | ៦៩.៧៦៨.០២៧.៣៨៧ | +១១.៧៦៨.០២៧.៣៨៧ |
| អតិរេកគណនេយ្យនៃចំណូល និង ចំណាយ | | ១.៨២៣.១៧៧.២៦១ | +១.៨២៣.១៧៧.២៦១ |
| កិច្ចប្រតិបត្តិការនៃថវិការបស់ខេត្ត ក្រុង | | | |
| I. ចំណូលថវិកា | ៥៨.០០០.០០០.០០០ | ៧១.៥៩១.២០៤.៦៤៨ | +១៣.៥៩១.២០៤.៦៤៨ |
| - ចំណូលចរន្ត | ៥៨.០០០.០០០.០០០ | ៦៦.០៩១.២០៤.៦៤៨ | +៨.០៩១.២០៤.៦៤៨ |
| • ចំណូលសារពើពន្ធ | ២៦.០០០.០០០.០០០ | ៣៤.០៩៧.៤៨៦.១០២ | +៨.០៩៧.៤៨៦.១០២ |
| • ចំណូលមិនមែនសារពើពន្ធ | ៦.០០០.០០០.០០០ | ៧.០៧៣.៧១៨.៥៤៦ | +១.០៧៣.៧១៨.៥៤៦ |
| • ឧបត្ថម្ភពីថវិការដ្ឋ | ២៦.០០០.០០០.០០០ | ២៤.៩២០.០០០.០០០ | -១.០៨០.០០០.០០០ |
| - ចំណូលជាមូលធន | ០ | ៥.៥០០.០០០.០០០ | +៥.៥០០.០០០.០០០ |
| • ចំណូលជាមូលធនផ្ទៃក្នុង | ០ | ០ | +០ |
| • ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ (កម្មវិធីសិលា) | ០ | ៥.៥០០.០០០.០០០ | +៥.៥០០.០០០.០០០ |
| II. ចំណាយថវិកា | ៥៨.០០០.០០០.០០០ | ៦៩.៧៦៨.០២៧.៣៨៧ | +១១.៧៦៨.០២៧.៣៨៧ |
| - ចំណាយចរន្ត | ៥៨.០០០.០០០.០០០ | ៦៤.២៨៦.០៥២.៩៨៥ | +៦.២៨៦.០៥២.៩៨៥ |
| - ចំណាយជាមូលធន | ០ | ៥.៤៨១.៩៧៤.៤០៨ | +៥.៤៨១.៩៧៤.៤០៨ |
| III. អតិរេកថវិកា | ០ | ១.៨២៣.១៧៧.២៦១ | +១.៨២៣.១៧៧.២៦១ |

**មាត្រា ៩.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ អតិរេកនៃថវិការបស់ខេត្ត ក្រុង ដែលមានចំនួនទឹកប្រាក់ ១.៨២៣.១៧៧.២៥១ រៀល ត្រូវបានបង់ចូលថវិកាទូទៅរបស់រដ្ឋ ។

## ជំពូកទី ៦
## បទប្បញ្ញត្តិស្តីពីនិយ័តភាវូបនីយកម្ម
## នៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១

**មាត្រា ១០.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែធ្នូឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩៩៩ និង អនុលោមតាមមាត្រា ១០ នៃច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០១ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ព្រមទាំងមាត្រា ១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ត្រូវបានយល់ព្រមផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដូចខាងក្រោមនេះ ៖

- ចំណាយសំរាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសរើសក្រុម

ប្រឹក្សាឃុំ-សង្កាត់ ត្រូវបានចេញអនុក្រឹត្យលេខ ១២១ អនក្រ-បក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្ដីពីការផ្ដល់ឥណទានថវិកាបន្ថែមលើឥណទានថវិការបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ចំនួន ៣០.០០០ លានរៀល ។

- ចំណាយសង្គ្រោះប្រជាជនរងគ្រោះដោយទឹកជំនន់ និងរាំងស្ងួតព្រមទាំងចំណាយសំរាប់ស្ដារហេដ្ឋារចនាសម្ព័ន្ធឡើងវិញក្រោយទឹកជំនន់ ត្រូវបានចេញអនុក្រឹត្យលេខ ១១២ អនក្រ-បក ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្ដីពីការផ្ដល់ឥណទានថវិកាបន្ថែមលើឥណទានថវិការបស់ទីស្ដីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ចំនួន ១៧.៥០០ លានរៀល ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**

**នរោត្ដម សីហមុនី**

*នស/រកម.០៥០៥.០២៣*

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ ៤៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឡុំ ឌីកាន់**

# ព្រះរាជក្រម

នស/រកម/០៥០៥/០១៣

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងមូលដ្ឋានស្តីពី កម្មវិធីសហប្រត្តិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO) ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងមូលដ្ឋានស្តីពីកម្មវិធីសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO)

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងមូលដ្ឋានស្តីពីកម្មវិធីសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO) ដែលធ្វើនៅសិង្ហបុរី នាថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៤.១៤៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល**
**ហត្ថលេខា**
**ស៊ុយ សែម**

លេខ ១៥១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ណាឌី តាន់**

3/3

# ពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងជាមូលដ្ឋានស្តីពីកម្មវិធីសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO)

រដ្ឋាភិបាលប្រទេសប្រ៊ុយណេ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ និង សាធារណរដ្ឋសង្គមនិយមវៀតណាម សមាជិករបស់សមាគមជាតិអាស៊ីអាគ្នេយ៍( អាស៊ាន)

**ការរំលឹកដល់** កិច្ចព្រមព្រៀងជាមូលដ្ឋានស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន AICO ចុះហត្ថលេខា ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦ នៅប្រទេសសិង្ហបុរី ដែលទីនេះហៅថា"កិច្ចព្រមព្រៀង" ដែលមានគោលបំណងផ្តល់នូវការចង្អុលបង្ហាញ និងក្របខ័ណ្ឌផ្លូវច្បាប់ ដែលក្នុងនោះផ្នែកឯកជនអាស៊ានអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នានៅលើមូលដ្ឋានយោគយល់គ្នា និង មានផលប្រយោជន៍ទៅវិញទៅមកសំរាប់ប្រទេស ជាសមាជិកអាស៊ាន និង បង្កើននូវផលិតផលឧស្សាហកម្មសំរាប់តំបន់ទាំងមូល ។

**ការយល់ដឹង** ជាមួយនឹងការពេញចិត្តដែលកម្មវិធី AICO បានទទួលជោគជ័យតាមគោលដៅរបស់ខ្លួន ។

៤ **ការកត់សំគាល់** ដូចគ្នាដែលមាត្រាទី១នៃពិធីសាធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីកម្មវិធី CEPT សំរាប់ AFTA ដើម្បីលុបបំបាត់ពន្ធនាំចូល បានចុះហត្ថលេខាថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៣ ធ្វើវិសោធនកម្មអត្រាពន្ធនៅទីបញ្ចប់នៃកម្មវិធី CEPT មកដល់ 0% ។

**ការរំលឹកដល់** ការសំរេចចិត្តនៃកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននៅ Genting Highland ប្រទេសម៉ាឡេស៊ី នៅខែ កក្កដា ឆ្នាំ២០០២ ដើម្បីធ្វើការរក្សានូវអ្វីដែលទាក់ទងដល់កម្មវិធី AICO ក្រោយ ២០០២ និងការប្រឹងប្រែងបញ្ចុះអត្រាពន្ធសំរាប់កម្មវិធី AICO ទៅដល់ 0% ។

**ការរំលឹកដល់** សេចក្តីសំរេចចិត្តរបស់កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៣៤ ដែលបានធ្វើឡើងនៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០២ នៅ Bandar Seri Begawan ប្រទេសប្រ៊ុយណេ ដើម្បីធ្វើការកែប្រែអត្រាពន្ធសមស្របទៅតាមប្រទេសសមាជិកដែលចូលរួមនៅក្នុងកម្មវិធី AICO ។

**ការទទួលស្គាល់** ការចាំបាច់ធ្វើអោយកិច្ចព្រមព្រៀងនៅតែមានភាពទាន់សម័យដើម្បីធ្វើការរក្សាវាអោយមាននិរន្តរភាពរហូតទៅក្រោយឆ្នាំ ២០០២ ។

**ការកត់សំគាល់** មាត្រា ១៣នៃកិច្ចព្រមព្រៀងអនុញ្ញាតអោយមានការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ។

**បានយល់ព្រមដូចខាងក្រោមនេះ**

## មាត្រា១

មាត្រា១ (និយមនយ័) នៃកិច្ចព្រមព្រៀងនឹងត្រូវបានធ្វើការកែប្រែដោយជំនួសមាត្រា១(៦) ដូចខាងក្រោមៈ

"៦. " អត្រាអនុគ្រោះពន្ធ " មានន័យថា ជាអត្រាអនុគ្រោះពន្ធនាំមុខចុងបញ្ចប់នៃអត្រា CEPT ដែលកំនត់ដោយប្រទេសជាសមាជិកចូលរួមត្រឹម 0% ដូចដែលមានចែងនៅក្នុងពិធីសារវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ ហើយដែលបានចែងច្បាស់នៅក្នុងមាត្រា២(៤)នៃពិធីការវិសោធនកម្មនេះ និងមាត្រា ៤ នៃកិច្ចព្រមព្រៀង"។

## មាត្រា២

មាត្រា២ (បទប្បញ្ញត្តិទូទៅ) នៃកិច្ចព្រមព្រៀងនឹងត្រូវបានធ្វើការកែប្រែដូចខាងក្រោមៈ

(ក) ដោយបញ្ចូលមាត្រាថ្មី ២(៤) បន្ទាប់ពីមាត្រាចាស់ ២(៣) ដូចខាងក្រោមនេះ:

" ៤. នៅក្នុងករណីដែលការរៀបចំកម្មវិធី AICO ត្រូវបានយល់ព្រមអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករាឆ្នាំ ២០០៣ អត្រាអនុគ្រោះពន្ធសំរាប់ប្រទេសជាសមាជិកនឹងត្រូវបានអនុវត្តនៅក្នុងអត្រាពន្ធកំនត់ដូចខាងក្រោមៈ

| | | |
|---|---|---|
| ក. ប្រទេសប្រ៊ុយណេ | - | 0% |
| ខ. ព្រះរាជាណាចក្រកម្ពុជា | - | 0% |
| គ. សាធារណរដ្ឋឥណ្ឌូនេស៊ី | - | 0% |
| ឃ. សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ | - | 0% |
| ង. ម៉ាឡេស៊ី | - | 0% |
| ច. សហភាពមីយ៉ាន់ម៉ា | - | 0-៥% |
| ឆ. សាធារណរដ្ឋហ្វីលីពីន | - | 0-១% |
| ជ. សាធារណរដ្ឋសឹង្ហបូរី | - | 0% |
| ឈ. ព្រះរាជាណាចក្រថៃឡង់ | - | 0-៣% |
| ញ. សាធារណរដ្ឋសង្គមនិយមវៀតណាម | - | 0-៥% |

ប្រទេសជាសមាជិកចូលរួម អាស្រ័យដោយមានការយោគយល់គ្នាទៅវិញទៅមក អាចបង្កើតកិច្ចព្រមព្រៀងទៅលើអត្រាអនុគ្រោះពន្ធរវាង ឬ ក្នុងចំណោមប្រទេសជាសមាជិកចូលរួមក្នុងកំរិតអត្រាពន្ធដូចមានចែងខាងលើនៃប្រទេសជាសមាជិកនិមួយៗ" ។

(ខ) ដោយដាក់បញ្ចូលមាត្រាថ្មី ២(៥)ដូចខាងក្រោមនេះ:

"៥. ប្រទេសជាសមាជិកអាស៊ានដូចមាននៅក្នុងមាត្រា ២ (៤) ដែលពួកគេស្ថិតនៅជាបណ្តោះអាសន្ន ពុំទាន់អនុវត្តអត្រាអនុគ្រោះពន្ធ0%នឹងត្រូវធ្វើការបញ្ចុះអត្រាអនុពន្ធរហូតដល់ 0%តាមកិច្ចព្រមព្រៀង AICO នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥លើកលែងតែសាធារណៈរដ្ឋវៀតណាមដែលនឹងត្រូវបញ្ចុះដល់ 0% នៅថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០៦" ។

## មាត្រា៣

មាត្រា៥(សិទ្ធិ) នៃកិច្ចព្រមព្រៀងនឹងត្រូវបានកែប្រែដោយជំនួសមាត្រា៥(១)(ក) ដូចខាងក្រោម:

" ក. ផលិតផល AICO ដែលបានអនុញ្ញាតធ្វើពាណិជ្ជកម្មរវាងក្រុមហ៊ុនដែលចូលរួមនឹងត្រូវបានទទួលនូវការអនុគ្រោះពន្ធដូចដែលបានកំនត់ច្បាស់នៅក្នុងមាត្រា១(៦) និង មាត្រា២(៤) តាមដែលអាចធ្វើទៅបាន។ នៅពេលណាដែលការកំណត់ការអនុគ្រោះពន្ធស្ថិតនៅក្នុងចន្លោះអត្រាពន្ធបានកំនត់ អត្រាពន្ធជាក់ស្តែងមួយត្រូវបានកំនត់ដោយប្រទេសជាសមាជិកចូលរួមនោះ។ អត្រាអនុគ្រោះពន្ធត្រូវបានបញ្ចប់នៅ-ពេលណាដែលអត្រាពន្ធនៃផលិតផលទៅដល់អត្រាចុងបញ្ចប់នៃអត្រា CEPT ។

## មាត្រា៤

មាត្រា៧ (បែបបទពាក្យសុំ) នៃកិច្ចព្រមពៀងនឹងត្រូវបានកែប្រែជំនួសដោយមាត្រា៧(២)ដូចខាង ក្រោម:

" ២. ប្រទេសជាសមាជិកអាស៊ានក្នុងរយៈពេល៦០ថ្ងៃនៃការទទួលពាក្យសុំត្រូវជូនដំណឹងដល់លេខាធិការដ្ឋានអាស៊ាននូវ:

ក. ការសំរេចចិត្តរបស់ខ្លួននៅក្នុងការចូលរួមក្នុងកម្មវិធី AICO និង

ខ. នៅពេលសមស្រប អត្រាអនុគ្រោះពន្ធត្រូវបានអនុវត្តដូចដែលបានកំនត់នៅក្នុងមាត្រា១(៦) និង មាត្រា ២(៤) ។

ប្រសិនបើមានប្រទេសជាសមាជិកអាស៊ានណាពុំអាចធ្វើការកំណត់លើការសំរេចចិត្តលើអត្រាពន្ធនៅក្នុងអំឡុងពេលនេះយ៉ាងណាក៏ដោយ នឹង ត្រូវតែផ្តល់ការសំរេចចិត្តរបស់ខ្លួនលើការទទួលយល់ព្រម ឬ មិនយល់ព្រមនៃការរៀបចំបង្កើតកម្មវិធី AICO និង ទទួលយល់ព្រម ឬមិនយល់

ព្រមលើផលិតផល ជាផលិតផល AICO ។

## មាត្រា៥

មាត្រា១២ (ការលុបចោលបទបញ្ញត្តិផ្សេងៗ) នៃកិច្ចព្រមព្រៀង នឹង ត្រូវបានកែប្រែដោយធ្វើការជំនួសពាក្យ "បញ្ចប់" នៅក្នុងឃ្លាទីពីរនៃមាត្រា ១២(ឈ) ដោយពាក្យ " តាមការវិវត្តជាក់ស្តែង " ។

## មាត្រា៦

ពិធីសារនេះ នឹង ចូលជាធរមាននៅថ្ងៃដែលផ្តល់សច្ចាបន័ទទួលស្គាល់តំកល់ទុក ឬ ការទទួលស្គាល់ដោយភាគីហត្ថលេខីនៃរដ្ឋាភិបាលទាំងអស់ជាមួយនឹងអគ្គលេខាធិការអាស៊ាន។

ពិធីសារនេះនឹងត្រូវបានតំកល់ទុកឯអគ្គលេខាធិការអាស៊ានដែលជាអ្នកមានភារកិច្ចចម្លងជូនទៅគ្រប់ប្រទេសជាសមាជិក។

**នៅចំពោះមុខសាក្សី** ដែលបានចុះហត្ថលេខាខាងក្រោម ដោយមានការអនុញ្ញាតដោយរដ្ឋាភិបាលនៃប្រទេសនិមួយៗបានចុះហត្ថលេខាលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងជាមូលដ្ឋានលើវិស័យសហប្រតិបត្តិការឧស្សាហកម្មអាស៊ាន។

ធ្វើនៅ ប្រទេសសឹង្ហបូរី ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ជាភាសាអង់គ្លេសតែមួយច្បាប់គត់។

ជ. រដ្ឋាភិបាលប្រទេសប្រ៊ុយណេ

Pehin Dato Abdul Rahman Taib
រដ្ឋមន្ត្រីឧស្សាហកម្ម និង ធនធាន ប្រុយណេដារូសាឡាម

ជ. រដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

Cham Prasidh
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជ. រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

Rini M. S. Soevandi
រដ្ឋមន្ត្រីឧស្សាហកម្ម និង ពាណិជ្ជកម្ម

ជ. រដ្ឋាភិបាលប្រជាមានិតប្រជាធិបតេយ្យឡាវ

Soulivong Daravong
រដ្ឋមន្ត្រីពាណិជ្ជកម្ម

ជ. រដ្ឋាភិបាលម៉ាឡេស៊ី

Dato's Seri Rafidah Aziz
រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

ជ. រដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

U Tin Winn
រដ្ឋមន្ត្រីសហប្រតិបត្តិការសេដ្ឋកិច្ច

ជ. រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

Cesar A. V. Purisima
រដ្ឋលេខាធិការពាណិជ្ជកម្ម និង ឧស្សាហកម្ម

ជ. រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបូរី

George Yong-Boon Yeo
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

ជ. រដ្ឋាភិបាលព្រះរាជាណាចក្រថៃឡង់

Watana Muangsook
រដ្ឋមន្ត្រីពាណិជ្ជកម្ម

ជ. រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

Truong Dinh Tuyen
រដ្ឋមន្ត្រីពាណិជ្ជកម្ម

# PROTOCOL
# TO AMEND THE BASIC AGREEMENT
# ON THE
# ASEAN INDUSTRIAL COOPERATION SCHEME

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Vietnam, Member States of the Association of South East Asian Nations (ASEAN);

RECALLING the Basic Agreement on the ASEAN Industrial Cooperation (AICO) Scheme signed on 27 April 1996 in Singapore, hereinafter referred to as "the Agreement" which aims to provide the guidelines and institutional framework within which the ASEAN private sector may collaborate on the basis of mutual and equitable benefits for the ASEAN Member Countries and increased industrial production for the region as a whole;

ACKNOWLEDGING with satisfaction that the AICO Scheme has met its set objectives;

NOTING also that Article 1 of the Protocol to Amend the Agreement on the CEPT Scheme for the AFTA for the Elimination of Import Duties signed on 31st January 2003 amended the final CEPT rate to zero percent (0%);

RECALLING the decision of the ASEAN Economic Meetings Retreat in Genting Highland, Malaysia in July 2002 to maintain the relevance of the AICO Scheme beyond 2002 and to work towards setting the AICO rate at zero percent (0%);

RECALLING the decision of the 34th Meeting of the ASEAN Economic Ministers (AEM) held on 12 September 2002 in Bandar Seri Begawan, Brunei Darussalam to amend the preferential tariff rates applicable to participating countries on the AICO Scheme;

RECOGNISING the need to update the Agreement to maintain its continued relevance beyond 2002;

NOTING that Article 13 of the Agreement provides for amendments to it;

HAVE AGREED AS FOLLOWS:

## ARTICLE 1

Article 1 (Definitions) of the Agreement shall be amended by substituting Article 1(6), with the following :

"6. "Preferential Tariff Rate" shall mean the advanced final CEPT rate fixed by Participating Countries at 0% as provided for by the Protocol to Amend the Agreement on the CEPT Scheme for the AFTA for the Elimination of Import Duty. This definition shall be read together with Article 2(4) of the Agreement agreed upon in this Protocol and Article 4 of the Agreement."

## ARTICLE 2

Article 2 (General Provisions) of the Agreement shall be amended as follows :

(a) by inserting a new Article 2(4) after existing Article 2(3) as follows :

"4. In the case of AICO Arrangements approved from 01 January 2003, the Preferential Tariff Rate for Participating Countries shall be within the band as follows :

| | | |
|---|---|---|
| a. Brunei Darussalam | - | 0% |
| b. The Kingdom of Cambodia | - | 0% |
| c. Republic of Indonesia | - | 0% |
| d. Lao People's Democratic Republic | - | 0% |
| e. Malaysia | - | 0% |
| f. Union of Myanmar | - | 0-5% |
| g. Republic of the Philippines | - | 0-1% |
| h. Republic of Singapore | - | 0% |
| i. The Kingdom of Thailand | - | 0-3% |
| j. Socialist Republic of Vietnam | - | 0-5% |

Participating Countries upon mutual agreement may establish preferential tariff rate arrangements between or amongst Participating Countries within the applicable bands stated above of the respective Participating Countries."

(b) by inserting the following new Article 2(5) as follows:

"5. The ASEAN Member Countries referred to in Article 2(4) that are temporarily not ready to implement the Preferential Tariff Rate of 0%, shall work towards reducing the Preferential Tariff Rate to 0% for

AICO Arrangements by 1 January 2005, whereas the Socialist Republic of Vietnam shall do so by 1 January 2006."

## ARTICLE 3

Article 5 (Privileges) of the Agreement shall be amended by substituting Article 5(1)(a) with the following :

"a. approved AICO Products traded between Participating Companies shall enjoy the Preferential Tariff Rate stipulated in Article 1(6) and Article 2(4), where applicable. Where the stipulated Preferential Tariff Rate is within a band, the actual rate shall be determined by that Participating Country concerned. The Preferential Tariff Rate shall cease when the tariff rate of the product reaches the final CEPT rate;"

## ARTICLE 4

Article 7 (Application Procedures) of the Agreement shall be amended by substituting Article 7(2) with the following :

"2. ASEAN Member Countries shall, within 60 days of receipt of the application, inform the ASEAN Secretariat of :

a. their decisions in participating in an AICO Arrangement; and,
b. where applicable, the Preferential Tariff Rate to be applied as stipulated in Article 1(6) and Article 2(4).

ASEAN Member Countries, where applicable, which are unable to indicate a decision on the tariff rate within this period shall nevertheless indicate their decision on acceptance or otherwise, of the arrangement and the product as an AICO Product."

## ARTICLE 5

Article 12 (Repealing Provision) of the Agreement shall be amended by replacing the word "final" in the second sentence of Article 12(d) with "prevailing".

ARTICLE 6

This Protocol shall enter into force on the date of deposit of the instruments of ratification or acceptance by all signatory governments with the Secretary-General of ASEAN.

This Protocol shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof to each Member Country.

IN WITNESS THEREOF, the undersigned, being duly authorised thereto by their respective Governments, have signed the Protocol to Amend the Basic Agreement on the ASEAN Industrial Cooperation Scheme.

DONE at Singapore, this 21st day of April 2004 in a single copy in the English Language.

For the Government of Brunei Darussalam

Pehin Dato Abdul Rahman Taib
Minister of Industry and Primary Resources, Brunei Darussalam

For the Government of the Kingdom of Cambodia

Cham Prasidh
Minister of Commerce

For the Government of the Republic of Indonesia

Rini M. S. Soewandi
Minister of Industry and Trade

For the Government of Lao People's Democratic Republic

Soulivong Daravong
Minister of Commerce

For the Government of Malaysia

Rafidah Aziz
Minister of International Trade and Industry

For the Government of the Union of Myanmar

U Tin Winn
Minister for Economic Cooperation

For the Government of the Republic of the Philippines

Cesar A. V. Purisima
Secretary of Trade and Industry

For the Government of the Republic of Singapore

George Yong-Boon Yeo
Minister for Trade and Industry

For the Government of the Kingdom of Thailand

Watana Muangsook
Minister of Commerce

For the Government of the Socialist Republic of Vietnam

Truong Dinh Tuyen
Minister of Trade

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើត **រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ** មានអក្សរកាត់ថា " **រ.ប.វ.ត.** " មានឋានៈស្មើរដ្ឋលេខាធិការដ្ឋាន ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ហើយស្ថិតនៅក្រោមវិសាលភាពនៃបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

**មាត្រា ២.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានផ្នែកបច្ចេកទេស ស្ថិតក្រោមអាណាព្យាបាលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង ផ្នែកហិរញ្ញវត្ថុ ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២
## បេសកកម្ម

**មាត្រា ៣.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានបេសកកម្មរៀបចំការប្រឡងប្រជែងជ្រើសរើស និង រៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សចៅក្រម និង សិស្សក្រឡាបញ្ជី ដែលបានជ្រើសរើសថ្មី ព្រមទាំងទទួលបន្ទុកបណ្តុះបណ្តាលបន្ត និងធ្វើវិក្រឹតការ ជូនដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ដែលកំពុងបំពេញការីយកម្ម ។

**មាត្រា ៤.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវសហការល្អជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួងយុត្តិធម៌ សាលាជំរះក្តីនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ស្ថាប័នតុលាការអន្តរជាតិ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈជូនដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ឱ្យឈានទៅជាបណ្តើរៗ រហូតមានកំរិតស្តង់ដារអន្តរជាតិ ។



3/7

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៥.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានរចនាសម្ព័ន្ធដូចខាងក្រោមៈ

- សាលាភូមិន្ទចៅក្រម
- សាលាភូមិន្ទក្រឡាបញ្ជី
- អគ្គលេខាធិការដ្ឋាន

## ជំពូកទី ៤
## តួនាទីភារកិច្ច

**មាត្រា ៦.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានតួនាទីភារកិច្ចដូចខាងក្រោមៈ

- រៀបចំផែនការមេនៃការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងក្រឡាបញ្ជី
- រៀបចំ និងអនុម័តផែនការសកម្មភាពអភិវឌ្ឍន៍នៅក្នុងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- កំណត់បែបបទនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និង សិស្សក្រឡាបញ្ជី
- ទំនាក់ទំនងធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងក្រឡាបញ្ជី
- អនុម័តបទបញ្ជាផ្ទៃក្នុង
- អនុម័តគំរោងថវិកាប្រចាំឆ្នាំ
- រាយការណ៍ជូនទីស្តីការគណៈរដ្ឋមន្ត្រី តាមកាលកំណត់។

## ជំពូកទី ៥
## ការគ្រប់គ្រងរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

**មាត្រា ៧.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល និង ប្រធាននៃរ.ប.វ.ត.មួយរូប ហើយមានអគ្គលេខាធិការមួយរូប ទទួលបន្ទុកគ្រប់គ្រងរដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ ព្រមទាំងពិនិត្យ និង សម្របសម្រួលការងាររវាងសាលាភូមិន្ទចៅក្រម និងសាលាភូមិន្ទក្រឡាបញ្ជី ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។



4/7

ប្រធាននៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរៈជនខ្មែរជាន់ខ្ពស់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសញ្ញាប័ត្រខ្ពស់ផ្នែក នីតិសាស្ត្រ ឬ ផ្នែកគ្រប់គ្រង ។

អគ្គលេខាធិការនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នាយកសាលាភូមិន្ទចៅក្រម និងនាយកសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨.-**

ក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវប្រជុំសាមញ្ញចំនួនបីដងក្នុងមួយឆ្នាំ ។ កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ក្រសួងយុត្តិធម៌ ។

**មាត្រា ៩.-**

ក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានសមាសភាពដូចតទៅ:

| | |
|---|---|
| ១. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣. ប្រធាននៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | សមាជិកស្វ័យប្រវត្តិ |
| ៤. តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មួយរូប | សមាជិក |
| ៥. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូប | សមាជិក |
| ៦. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី មួយរូប | សមាជិក |
| ៧. តំណាងក្រសួងយុត្តិធម៌ មួយរូប | សមាជិក |
| ៨. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មួយរូប | សមាជិក |
| ៩. ចៅក្រម តុលាការកំពូល មួយរូប | សមាជិក |
| ១០. ចៅក្រម សាលាឧទ្ធរណ៍ មួយរូប | សមាជិក |
| ១១. តំណាងអគ្គស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មួយរូប | សមាជិក |
| ១២. នាយកសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | សមាជិកអញ្ជើញ |
| ១៣. នាយកសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | សមាជិកអញ្ជើញ |

១៤. អគ្គលេខាធិការនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សមាជិកអញ្ជើញ

សមាជិកអញ្ជើញត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែពុំមានសិទ្ធិធ្វើការបោះឆ្នោតអនុម័តអ្វីឡើយ ។

សមាសភាពក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងដោយអនុក្រឹត្យ ។

## ជំពូកទី ៦
## ធនធានហិរញ្ញវត្ថុ

**មាត្រា ១០.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានថវិកាស្វយ័ត ដែលផ្គត់ផ្គង់ដោយថវិកាជាតិ ។ រ.ប.វ.ត. មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពផ្សេងៗ សំរាប់ការចំណាយលើដំណើរការបណ្តុះបណ្តាល សេវារដ្ឋបាល ផ្គត់ផ្គង់សំភារៈបរិក្ខារ និងការឧបត្ថម្ភផ្សេងៗ តាមការចាំបាច់ ក្នុងគោលដៅធានាប្រសិទ្ធភាពការងាររបស់ខ្លួន ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ១១.-**

ក្នុងកាលៈទេសៈចាំបាច់ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អាចទទួលបន្ទុករៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការឯកទេសផ្សេងៗទៀត និងអ្នកជំនួយការតុលាការ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៣.-**

សម្តេចនាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមស្មារតីនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៤.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០០៥*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នស/រកត.០៥០១.០២២*

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ ៩៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ាវ ណាន់**

***កន្លែងទទួល :***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- លេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និង ស្ថាប័នរដ្ឋ
- ឯកសារ- កាលប្បវត្តិ

5

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៥/១៩១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោក ជឹម ចិន្ទរ័ត្នមុនី ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៤.២០៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៥*

លេខ : ១៩១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

## ទ្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ស៊ូ គីរិន្ទ

នូវ

## គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា

## ថ្នាក់ ធិបឌិន្ទ

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៥

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៥០៥.២១៦

លេខ: ១៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

B.173

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២០៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

ក-ថ្នាក់ឧត្តមសេនីយ៍ឯក :

១-លោកឧត្តមសេនីយ៍ទោ រ៉េយ៉ម គឿង អត្តលេខ ០១១១

២-លោកឧត្តមសេនីយ៍ទោ គន្ធ ដំរឿន អត្តលេខ ០០៥២

ខ-ថ្នាក់ឧត្តមសេនីយ៍ត្រី :

-លោកវរសេនីយ៍ឯក ឃុន សំបូរ អត្តលេខ ០៦៩៣ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៥*
*ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់*

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រ/ល ០៥០៥-២១៧
លេខ : ១៨៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

2/2

**សុខ តាន់**

នស/រកត/០៥០៥/២០៥

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **មាស សារិន** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០៥

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

ចរល-០៥០៥-២១៧

លេខ: ១៨៧ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាវី តាន់

2/2

នស/រកត/០៥០៥/២០៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

## ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម **ហេង វង្សប៊ុនឆាត**

ទីប្រឹក្សារាជរដ្ឋាភិបាល

នូវ

## គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា

## ថ្នាក់ មហាសេនា

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាសបង្គាប់ ៍

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

ពរល.០៥០៥.២១៩

លេខ : ១៧៥៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាន់ តាន់**

B.174

៤

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/ ២០៦ ស្តុន

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

Son Excellence Monsieur CLAUDE GOUR

Conseiller Juridique du Gouvernement

Royal du Cambodge

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា

ថ្នាក់ សេនា

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ចរល.០៥០៥.២១៩ ស្តុន

លេខ ១៥៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

នស/រកត/០៥០៥/២០៧

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានតូបិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើប្រាស់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **ឡុង លឹម** អត្តលេខ ០៧៦៩ នាយនគរបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥*

*ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់*

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រល.០៥០៥.២២០

លេខ: ១៥៣ ចល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាន់ ឌី តាន់**

ង២

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២០៨

## យើង

ព្រះករុណាព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងសំរូលភារកិច្ចជូន ឯកឧត្ដមចំនួន ២រូប ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្ដម ប៊ុន ភារិន បច្ចុប្បន្នជានាយកវិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេស ទៅជានាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

២-ឯកឧត្ដម ប៉ុក ឆិន បច្ចុប្បន្នជាអគ្គនាយករងនៃអគ្គនាយកដ្ឋានឧត្ដមសិក្សា ទៅជានាយកវិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេស មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ :** សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០០៥

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល-០៥០៥.២២១

លេខ : ១៤៦៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

នស/រកត/០៥០៥/២០៩

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៧២ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៤ ស្តីពីការតែងតាំងសមាសភាពនៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង :

១-ឯកឧត្តម **ជៀប ស៊ីវន** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

២-ឯកឧត្តម **អ៊ឹង មល្លីវណ្ណ** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

៣រ.ល.០៥០៥.២៦៦

លេខ ៦៧១ ច.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សាទី តាន់**

42

នស/រកត/០៥០៥/២១០

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្ រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងលោកជំទាវ គីម នាង ជាឧបការីសម្តេចក្រុមព្រះ សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ទទួលបន្ទុកការងារក្រុមប្រឹក្សាអភិវឌ្ឍន៍ប្រទេសកម្ពុជា ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០០៥*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣រល.០៥០៥.២២៣

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ ១៧៩៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាន់ ឌី (?)

២/២

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

**ត្រាស់ព្រះរាជទាន**

ចំពោះ

ឯកឧត្តម **មិន យិន**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា**

**ថ្នាក់ មហាសេនា**

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

ចរល-០៥០៥.៦២៥

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥*

លេខ ១០៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈឹម តាន់

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៥០...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល អគ្គនាយក និង មន្ត្រីត្រួតពិនិត្យរដ្ឋ នៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រ៉េ"

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រ៉េ"
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១:** តែងតាំងសមាភាពក្រុមប្រឹក្សាភិបាល អគ្គនាយក និងមន្ត្រីត្រួតពិនិត្យរដ្ឋ នៃក្រុមហ៊ុនធានារ៉ាប់រងបន្ត កម្ពុជា ហៅកាត់ថា "**កម្ពុជា រី**" ដូចមាននាមខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាប្រធាន |
| ២- ឯកឧត្តមបណ្ឌិត **ឌា វ៉ាន់ដេត** | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៣- ឯកឧត្តម **ខៀវ សារ៉េត** | អគ្គាធិការកិច្ចការតុលាការនៃក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៤- លោក **វង្ស ម៉ុនឥន្ទ្រាវុធ** | អនុប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក និងជាអគ្គនាយក |
| ៥- លោក **នេត មុន្នី** | អនុប្រធានទី១នៃនាយកដ្ឋានទ្រព្យរដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាមន្ត្រីត្រួតពិនិត្យរដ្ឋ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា និង សាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវបំពេញភារៈកិច្ចរបស់ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៩១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០៩គ្រឿង បំពាក់ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគធនធាន ជួយកសាងសាលាភត្ត ០១ខ្នង នៅវត្តប្រាសាទ ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយព្រះនាម និងនាម ខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

-ព្រះតេជគុណ **សោម ជា** ចៅអធិការវត្តប្រាសាទ បច្ច័យ ចំនួន ៤៣.៥០០ ដុល្លារ

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឯកឧត្តម **សូ ផន** នៅក្រុងភ្នំពេញ ថវិកា ចំនួន ៧.០០០ ដុល្លារ

២-លោក **ឡាយ ឈុនសារេត** នៅក្រុងភ្នំពេញ ថវិកា ចំនួន ៧.០០០ ដុល្លារ

៣-ឧបាសិកា **ឌុក ឆន** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៧.០០០ ដុល្លារ

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-អ្នកស្រី **តាំង សារី** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣.០០០ ដុល្លារ

២-អ្នកស្រី **ឈុន គេងឡាង** នៅក្រុងភ្នំពេញ ថវិកា ចំនួន ២.៥០០ ដុល្លារ

| | | | | |
|---|---|---|---|---|
| ៣-លោក | **គន់ មាន** | នៅប្រទេសអង់គ្លេស | ថវិកា ចំនួន | ១.៥០០ ដុល្លារ |
| ៤-លោក | **ហុង រ៉ាឌុច** | នៅក្រុងភ្នំពេញ | ថវិកា ចំនួន | ១.៥០០ ដុល្លារ |
| ៥-លោកស្រី | **ជា ស៊ីនលី** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន | ១.៥០០ ដុល្លារ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៩៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ
- បង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **Murakami Katsumi** ជំនាញការស្ម័គ្រចិត្តរបស់អង្គការសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (Senior Volunteers of JICA ) ដែលបានចូលរួមសហការការងារ ជាមួយមជ្ឈមណ្ឌលបញ្ជូនស៊ីញ៉ាល់នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស សម្រេចបានលទ្ធផលល្អប្រសើរ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤២៣ អនក្រ-តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនដើម្បីជួយកសាងសមិទ្ធផលនានា និង ជួសជុលផ្លូវ ព្រមទាំងចែកអំណោយដល់ជនក្រីក្រ ស្ថិតនៅក្នុងស្រុកពារាំង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ÷

១-ឯកឧត្តម **លឹម ស៊ីវឌីន** អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ថវិកា ១៧.៤០០ USD

២-ឯកឧត្តម **ម៉ៅ ធនិន** ទីប្រឹក្សាសម្តេច ជា ស៊ីម ថវិកា ១០.៩០០ USD

៣-ឯកឧត្តម ឧត្តមសេនីយទោ **ខេង ពិសេស** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ថវិកា ១៤.៥០០ USD

៤-លោក **ឌី សុផល** ជំនួយការឯ.ឧ ជា សុន នាយកខុទ្ទកាល័យសម្តេចជា ស៊ីម ថវិកា ១២.៣៥០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤៦៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូន **Mr.JOHN STELLWAGEN** ជនជាតិដាណឺម៉ាក ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់នៃគំរោងអភិវឌ្ឍន៍សមត្ថភាពជាតិ-ដានីដា ដែលមានស្នាដៃ លើការអភិវឌ្ឍន៍ធនធានមនុស្ស ជូនដល់មន្ត្រីរាជការចំនួន ០៦ ស្ថាប័ន រយៈពេល ០៤ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៥៦១ ប្រ.ក

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ

*************

## ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញអនុក្រឹត្យ លេខ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៥ របស់លោក ស៊ុម ស៊ីថា ប្រធានគណបក្សប្រជាជាតិខ្មែរ អក្សរកាត់(គ.ប.ជ.ខ) ។

## សម្រេច

ប្រការ១ : ត្រូវបានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ **គណបក្សប្រជាជាតិខ្មែរ** ដែលមានទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ ដេ៩ E៤ ផ្លូវលេខ១៣០ ភូមិទី២ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ២ : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល និងគណបក្សប្រជាជាតិខ្មែរ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា និងឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០០៥

ស ខេង
ឧបនាយករដ្ឋមន្ត្រី.សហរដ្ឋមន្ត្រី

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

"ដើម្បីជូនជ្រាប"

- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ២

"ដើម្បីអនុវត្ត"

- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពត៌មាន**
**MINISTRY OF INFORMATION**

លេខ ១៦៤/០៥ ព.ម.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពីការបង្កើតការិយាល័យទូរទស្សន៍ជាតិកម្ពុជា

## តាមបណ្តាខេត្ត-ក្រុង

## រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ន/ស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន
- បានឃើញអនុក្រឹត្យលេខ ២០អនក្រ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧០អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពតិមាន
- បានឃើញប្រកាសលេខ ០១៧.០៣ ព.ម.ប្រ.ក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

## សំរេច

## ជំពូកទី១

**ប្រការ១. គោលបំណង នៃការបង្កើតការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង គឺ ៖**

-ផ្តល់អោយជាអតិបរមា នូវផលចំណេញដោយសមហេតុសមផលជូនដល់ប្រជាជនគ្រប់រូប

-ធានាការអនុវត្តន៍នូវសេរីភាព នៃការបញ្ចេញយោបល់តាមរយៈការផ្សព្វផ្សាយដោយធានាអោយបាននូវភាពមិនលំអៀង ភាពត្រឹមត្រូវ និងស្វ័យភាពរបស់ការផ្សាយ

-ធ្វើអោយការផ្សាយ បានរួមវិភាគទានដល់ការអភិវឌ្ឍន៍នូវលទ្ធិប្រជាធិបតេយ្យដ៏ល្អប្រសើរ ដោយបែងចែកអោយច្បាស់នូវការទទួលខុសត្រូវរបស់បុគ្គលទាំងអស់ដែលបំពេញការងារនៅក្នុងវិស័យផ្សព្វផ្សាយ ។

**ប្រការ២.**

**ត្រូវបានបង្កើតការិយាល័យទូរទស្សន៍ជាតិកម្ពុជា តាមបណ្តាខេត្ត-ក្រុងដូចខាងក្រោម ÷**

១.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ក្រុងព្រះសីហនុ

២.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តបាត់ដំបង

៣.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តសៀមរាប

៤.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តពោធិសាត់

៥.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តកោះកុង

៦.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តរតនៈគីរី

៧.ការិយាល័យទូរទស្សន៍ជាតិកម្ពុជា ខេត្តមណ្ឌលគីរី

**ប្រការ៣.**

ការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ដូចមានចែងក្នុងប្រការ២ ត្រូវស្ថិតនៅក្រោមចំណុះមន្ទីរនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ។

**ប្រការ៤.**

**ការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុងមានភារកិច្ច ÷**

-ផ្សព្វផ្សាយបន្តទាំងស្រុងពីអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

-អនុវត្តការសំរេចចិត្តពីអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា សំរាប់ការផ្សាយកម្មវិធីមូលដ្ឋាន

-អនុវត្តការសំរេចចិត្តពីអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជានូវការងារបុគ្គលិក-គណនេយ្យ ផែនការ ហិរញ្ញវត្ថុ បច្ចេកទេស និង ការងារធុរៈកិច្ច

-អាចសហការជាមួយមន្ទីរព័ត៌មានខេត្ត-ក្រុង និងសហការជាមួយឯកជន NGOs-OI ដើម្បីផលិតកម្មវិធីសមស្រប ។

ការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិយាល័យ ( រដ្ឋបាលកណ្តាល ) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ ( រដ្ឋបាលកណ្តាល ) ។

**ជំពូកទី២**

**ប្រការ៥.**

**ត្រូវបានបង្កើតការិយាល័យនិងតំណាងទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ក្រោមចំណុះមន្ទីរ និងនាយកដ្ឋាននានា ដូចខាងក្រោម ÷**

**ក.មន្ទីរ**

១.ការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង

**ខ.នាយកដ្ឋានពតិមានទូរទស្សន៍ក្នុង និងក្រៅប្រទេស**

១.ការិយាល័យទំនាក់ទំនងការងារពតិមានទូរទស្សន៍ក្នុង និងក្រៅប្រទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង

**គ.នាយកដ្ឋានផលិតកម្មវិធីទូរទស្សន៍**

១.ការិយាល័យទំនាក់ទំនងការងារផលិតកម្មវិធីជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង

**ឃ.នាយកដ្ឋានបច្ចេកទេសទូរទស្សន៍ជាតិកម្ពុជា**

១.ការិយាល័យទំនាក់ទំនងការងារបច្ចេកទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង

**ប្រការ៦.**

**ការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុងមានភារកិច្ច** ÷

-គ្រោងចំណូល និងចំណាយប្រចាំឆ្នាំសំរាប់ទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង

-គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌ ការិយាល័យទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង

-ធ្វើផែនការបណ្តុះបណ្តាលជំនាញទូរទស្សន៍ និងការបំពាក់សំភារៈបច្ចេកទេសទូរទស្សន៍ព្រមទាំងការជួសជុល

-ទំនាក់ទំនងសាធារណៈទីផ្សារ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ។

ការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាតាមបណ្តាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិយាល័យ( រដ្ឋបាលកណ្តាល) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ ( រដ្ឋបាលកណ្តាល ) ។

**ប្រការ៧.**

**ការិយាល័យទំនាក់ទំនងការងារពតិមានទូរទស្សន៍ក្នុង និងក្រៅប្រទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង មានភារកិច្ច** ÷

តាមរយៈការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាសហការជាមួយ ÷

-ផ្គត់ផ្គង់ពតិមានគ្រប់វិស័យតាមមូលដ្ឋាន តាមរយៈកាសែត ( Tape )

-បញ្ជូនពតិមានដោយផ្ទាល់គ្រប់វិស័យតាមរយៈការផ្សាយផ្ទាល់ ( តាមទូរស័ព្ទ ឬតាមឧបករណ៍ផ្សាយផ្ទាល់ )

-ជំរុញ និងលើកកំពស់ការងារជាមួយសហសេវិកតាមមូលដ្ឋាន ។

ការិយាល័យទំនាក់ទំនងការងារពតិមានទូរទស្សន៍ក្នុង និងក្រៅប្រទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិ យាល័យ ( រដ្ឋបាលកណ្តាល ) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ ( រដ្ឋបាលកណ្តាល ) ។

**ប្រការ៨.**

**ការិយាល័យទំនាក់ទំនងការងារផលិតកម្មវិធីទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុងមានភារកិច្ច ÷**

តាមរយៈការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង សហការជាមួយ ÷

-ផ្គត់ផ្គង់កម្មវិធីកំសាន្ត អប់រំ ឯកសារ កុមារ....។ល។

-ផ្តល់តារាងរៀបចំកម្មវិធីប្រចាំសប្តាហ៍

-ស្រាវជ្រាវទស្សនៈទស្សនិកជនរបស់មូលដ្ឋាន និងសិទ្ធិផ្សព្វផ្សាយ ។

ការិយាល័យទំនាក់ទំនងការងារផលិតកម្មវិធីទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) ។

**ប្រការ៩.**

**ការិយាល័យទំនាក់ទំនងការងារបច្ចេកទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុងមានភារកិច្ច ÷**

តាមរយៈការិយាល័យចាត់ចែងទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង សហការជាមួយ ÷

-ធ្វើផែនការថែទាំ និង ជួសជុលសំភារៈបច្ចេកទេស

-ត្រួតពិនិត្យស្ថានភាពប្រតិបត្តិការ និងបច្ចេកទេសផលិត និងផ្សាយ

-ធ្វើផែនការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាពត៌មាន (ICT)

ការិយាល័យទំនាក់ទំនងការងារបច្ចេកទេសជាមួយទូរទស្សន៍ជាតិកម្ពុជាខេត្ត-ក្រុង ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិយាល័យ ( រដ្ឋបាលកណ្តាល ) អមដោយនាយរងការិយាល័យមួយចំនួនតាមការចាំបាច់ និងមានមុខតំណែងជាអនុប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) ។

**ប្រការ១០.**

ឧបសម្ព័ន្ធនៃប្រកាសលេខ ០១៧.០៣ ព.ម.ប្រ.ក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៣ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ត្រូវទុកជានិរាករណ៍ ។

**ប្រការ១១.**

អង្គការលេខរបស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (TVK) ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ១២.**

អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ( TVK ) គ្រប់អគ្គនាយកដ្ឋានចំណុះក្រសួងពត៌មាន និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

**ចំលងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រាជកិច្ច

-ឯកសារ

ឧបសម្ព័ន្ធនៃប្រកាសលេខ ១២៤/០៥ ព.មប្រក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៥

អង្គការលេខនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៩១៦ ពណ.នតក

ភ្នំពេញថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វណ្ណ ថុង អ៊ីមផត អិចផត**

**WAN THONG IMPORT EXPORT Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7655/05P ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ឡា ធីហ៊ាន**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣០៨ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាដឹកជញ្ជូននិងវេចខ្ចប់ទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រង ខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ. ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម ស៊ីថន**

**<u>ចំលងជូន</u>**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសុខាភិបាល

ក្រសួងទេសចរណ៍

ក្រសួងពត៌មាន

ធនាគារជាតិនៃកម្ពុជា

ក្រសួងអប់រំយុវជន និងកីឡា

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ក្រសួងសាធារណការ និងដឹកជញ្ជូន

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ

សាលាក្រុងភ្នំពេញ

មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"

ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៩១៧ ពណ.នគក

ភ្នំពេញថ្ងៃទី ២៥ ខែ ៣ ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **សាមាតូ**

**SAMATOA Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2351/05E** ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **AWEN DELAVAL**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៣៤.៤០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិព្រែកថ្មី ឃុំសណ្តាន់ ស្រុកពួក ខេត្តសៀមរាប

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការដួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសដុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនតាមទឹកទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តសៀមរាប
- មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤២០ ពណ.នគក

ភ្នំពេញថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៥

# ដែសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស ខេ ខេ (ខេមបូឌា)**

**S K K ( CAMBODIA ) Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7643/05P ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **សេង ហួត** ប្រធានក្រុមប្រឹក្សាភិបាល

លោក **គួច ឡាច័ណ្ឌរ៉េង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៣១ FEo ផ្លូវលេខ ១០៩ សង្កាត់អូរឫស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ័រណ អាហ័រណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទូរផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក់វៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤១ ពណ.នគក

ភ្នំពេញថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **(ខេមបូឌា) មេថិល ទើក**

**(CAMBODIA) METAL WORK Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2347/05E** ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៥

មានទម្រង់ជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក WIPHON CHINPATTANAKUN ប្រធានក្រុមប្រឹក្សាភិបាល
លោក **រី ប៊ុនឈេង** អភិបាល
លោក CHETPONG NARKTRAKULBHANT អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ១ ក្រុមទី៤៧ ផ្លូវលេខ២៤០ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូលប្រេងឥន្ធនៈ ឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការដូលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដួសដុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកវិនិយោគនិងពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត និង...

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
ក្រសួងពាណិជ្ជកម្ម
ប្រធានខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋាន និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៦៦ ពណ.នគក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ភ្នំពេញថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេ ធី ស៊ី អ៊ិនធើណេសិនណល**

**K T C INTERNATIONAL CO.,LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7663/05P ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក MYUNG IL KIM ប្រធានក្រុមប្រឹក្សាភិបាល

លោក JONG CHUL HONG " គតិយជន " អភិបាល

លោក MAENG SU KIM " គតិយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៥ ផ្លូវ សុរាម្រឹត សង្កាត់ចតុមុខ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ទិញ លក់ និង អភិវឌ្ឍន៍អាជីវកម្មផ្នែកអចលនៈវត្ថុ

-នាំចេញ នាំចូល និង ឃោសនាផ្សព្វផ្សាយជំរុញការលក់ផលិតផល WIRE AND CABLE រួមទាំងផលិតផលពាក់ព័ន្ធ

-ចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មស្របច្បាប់នានាដែលទាក់ទងនឹងកម្មវត្ថុអាជីវកម្មខាងលើ ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៕

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

កឹម_ស៊ីថន

**ចំលងជូន**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពត៌មាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៩៧៣ ពណ.នគក,

ភ្នំពេញថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដ្រេហ្គន អនិសថ៍ អ៊ិនដាស្ទ្រី**
**DRAGON HONEST INDUSTRY Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 7653/05P ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ហេង សុខម៉េង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦ ផ្លូវលេខ ៣០០ សង្កាត់បឹងកេងកងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនឥវ៉ាន់ទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
